# សិក្ខាសាលាឆ្លុះបញ្ចាំង
## ការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម សម្រាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

២៥-២៦ កុម្ភៈ ២០១៥

# មាតិកា

១. ប្រវត្តិគម្រោង

២. បទពិសោធន៍ (ជោគជ័យ)

- អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF)
- ការពង្រឹងសមត្ថភាព
- កិច្ចប្រជុំផ្សព្វផ្សាយ
- ការដាក់ពិន្ទុ
- កិច្ចប្រជុំចាត់អាទិភាពសកម្មភាពតាមវិស័យ
- កិច្ចប្រជុំរួម និងផែនការសកម្មភាពគណនេយ្យភាពរួម (ផ.ស.គ.រ/JAAP)

៣. បញ្ហាប្រឈម

៤. ចំណុចកែលំអ

2

# ប្រវត្តិគម្រោង

ផែនការយុទ្ធសាស្ត្រ នៃការងារគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យមានគោលបំណងដូចខាងក្រោម៖

"ផ្តល់នូវ**<u>សិទ្ធិអំណាច</u>**ដល់ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន ជាពិសេសក្រុមដែលតំណាងឲផលប្រយោជន៍របស់ស្ត្រី យុវវ័យ និង ក្រុមជនងាយរងគ្រោះនានា ក្នុង**<u>ការចូលរួម</u>**ពង្រឹងការចាត់ចែង ការប្រើប្រាស់ថវិកា និងផ្តល់សេវាសាធារណៈនៅមូលដ្ឋាន តាមរយៈការលើកកម្ពស់នូវភាពងាយទទួលបានព័ត៌មាន និងការចូលរួម**<u>ពិនិត្យតាមដាន</u>**លើការងារថវិកា និងការបំពេញ

3

# ប្រវត្តិគម្រោង

- បន្សុីគ្នាទៅនឹងគោលបំណងនៃគម្រោង PROCEED "លើកកម្ពស់សិទ្ធិចូលរួមរបស់ប្រជាពលរដ្ឋដើម្បីអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ"
- ពីខែវិច្ឆិកាឆ្នាំ២០១៤ ដល់ ខែកុម្ភៈឆ្នាំ២០១៥៖ អង្គការផេក និង លេខាធិការដ្ឋាន គ.ជ.អ.ប ឧបត្ថម្ភដោយអង្គការយូនីសេហ្វ គាំទ្រលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការដាក់ពិន្ទុសេវាអប់រំ មណ្ឌលសុខភាព និងឃុំ ក្នុងស្រុកចំនួន៥៖ ពេជ្រាដា ព្រៃឈរ ក្រគរ សង្កែ និងថ្មគោល ៣៩ឃុំ និង គម្រោង PROCEED ចូលរួមថវិកាគាំទ្រ ១០ឃុំផ្សេងទៀត

4

## បទពិសោធន៍ - អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAFs)

- ការជ្រើសរើសអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAFs) ចំនួន ១២៦នាក់ (ស្ត្រី៤៣%)ក្នុងនោះ១០៨ (ស្រី ៤៣) បានជ្រើសរើសមកពីអ្នកដឹកនាំនៃបណ្តាញអង្គការសហគមន៍មូលដ្ឋាន
- វគ្គតម្រង់ទិស ស្តីពីទស្សនទាននៃការតាមដាន ដំណើរការ និងការទទួលខុសត្រូវដល់អ្នកពាក់ព័ន្ធចំនួន៥៥ឃុំៈ
  - អ្នកផ្តល់សេវាទាំងបីចំនួន ៥៩១នាក់
  - CAFs ចំនួន១១២នាក់ (ស្ត្រី ៥២នាក់)
  - បុគ្គលិក NGO ក្នុងស្រុកចំនួន ២៧នាក់

5

## បទពិសោធន៍-ការពង្រឹងសមត្ថភាព CAFs

- CAFsគួរជ្រើសរើសពីប្រជាពលរដ្ឋសកម្មនៅក្នុងសហគមន៍
- បណ្តុះបណ្តាលខ្លីៗ និងអនុវត្តជាក់ស្តែង
- ការបង្ហាត់បង្ហាញទៀងទាត់ជួយឲ CAFs មានសត្ថភាព និងជឿជាក់ក្នុងការសម្របសម្រួលដំណើរការប័ណ្ណដាក់ពិន្ទុសហគមន៍
- CAFs ជាស្ត្រីចំនួន៤៣%

6

# បទពិសោធន៍-ការពង្រឹងសមត្ថភាព CAFs

សកម្មភាពបណ្តុះ បណ្តាលនៅក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី (ត្វេង)





សកម្មភាព បណ្តុះបណ្តាល នៅស្រុកសង្កែ (ស្ពាំ)

**សកម្មភាពបណ្តុះបណ្តាលដល់ CAFs ភ្នាក់ងារ ផ្តល់សេវា និងអង្គការមិនមែនរដ្ឋាភិបាលដទៃនៅក្នុងមូលដ្ឋាន**

# បទពិសោធន៍-ការពង្រឹងសមត្ថភាព CAF



សកម្មភាពពបណ្តុះបណ្តាល នៅស្រុកសង្កែ ខេត្តបាត់ដំបង



សកម្មភាពបណ្តុះបណ្តាល ស្រុកព្រៃឈរ

**សកម្មភាពបណ្តុះបណ្តាលសមត្ថភាព CAFs របស់អង្គការដៃគូ នៅសហគមន៍**

8

## បទពិសោធន៍-កិច្ចប្រជុំផ្សព្វផ្សាយ

- កិច្ចប្រជុំផ្សព្វផ្សាយថ្នាក់ស្រុក និងឃុំជួយឲអ្នកពាក់ព័ន្ធបានដឹង និង គាំទ្រ ដំណើរការប័ណ្ណដាក់ពិន្ទុ ពិសេសការិយាល័យអប់រំស្រុក សុខា  ភិបាល និងរដ្ឋបាលស្រុក
- ចាំបាច់ត្រូវអញ្ជើញអង្គការពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយ
- មានលិខិតអញ្ជើញពីរដ្ឋបាលស្រុកដល់អ្នកផ្តល់សេវាទាំងបី
- ផ្តល់ព័ត៌មានទៅរដ្ឋបាលស្រុកពីកាលវិភាគនៃការអនុត្តដំណើរការប័ណ្ណដាក់ពិន្ទុ

9

## បទពិសោធន៍-ការដាក់ពិន្ទុ ដោយប្រជាពលរដ្ឋ

- ផ្សព្វផ្សាយព័ត៌មានស្តង់ដារ (I4C)ឲបានច្រើនដង មុនពេលដាក់ពិន្ទុធ្វើឲអ្នកចូលរួមយល់ដឹង និងងាយស្រួលក្នុងការកំណត់លក្ខណៈវិនិច្ឆ័យ
- ប្រជាពលរដ្ឋចូលរួមដាក់ពិន្ទុលើសេវាទាំង៣ជាមធ្យមមានចំនួន ១៧នាក់ (ស្រី១១នាក់) ជនងាយរងគ្រោះ ៥នាក់ និងយុវជន ៩នាក់
- ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធរៀនសូត្រ ពីយន្តការទំនាក់ទំនងថ្មីមួយទៀត
- ប្រជាពលរដ្ឋមានឱកាសដាក់ពិន្ទុ និងស្គាល់អ្នកផ្តល់សេវាទាំងបី
- ជនជាតិដើមភាគតិចជួយបកប្រែភាសាក្នុងដំណើរការប័ណ្ណដាក់ពិន្ទុ

10

# បទពិសោធន៍-ការដាក់ពិន្ទុ



*ប្រជាពលរដ្ឋ សិស្សានុសិស្សដាក់ពិន្ទុ សេវាសាលាបឋមសិក្សា ស្រុកព្រៃឈរ*



*សកម្មភាពដាក់ពិន្ទុខ្លួនឯង របស់មន្ត្រីសុខាភិបាល ឃុំ បឹងកន្ទួត ស្រុកក្រគរ*

# បទពិសោធន៍-ការដាក់ពិន្ទុដោយអ្នកផ្តល់សេវា

- ក្រុមប្រឹក្សា សាលារៀន មណ្ឌលសុខភាព និង អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ បានបែងចែកអ្នកទទួលខុសត្រូវក្នុងការកៀរគរប្រជាពលរដ្ឋចូលរួមដាក់ពិន្ទុ
- អ្នកផ្តល់សេវាមានភាពស្ទាក់ស្ទើរក្នុងការដាក់ពិន្ទុខ្លួនឯង និងភាគច្រើនដាក់ពិន្ទុខ្ពស់
- អ្នកផ្តល់សេវាមានទំនោរប្តូរឥរិយាបទបន្ទាប់ពីការដាក់ពិន្ទុខ្លួនឯង

12

## បទពិសោធន៍-ការដាក់ពិន្ទុ

ប្រជាពលរដ្ឋដាក់ពិន្ទុ ក្រុមប្រឹក្សា ឃុំបឹងព្រីង ស្រុកថ្មគោល





ប្រជាពលរដ្ឋដាក់ពិន្ទុលើសេវាសុខាភិបាលឃុំមៀន ស្រុកព្រៃឈរ

13

## កិច្ចប្រជុំចាត់អាទិភាពសកម្មភាពតាមវិស័យ

- ប្រជាពលរដ្ឋ និងអ្នកផ្តល់សេវា មានឱកាសពិភាក្សា និងបានយល់ពីមូលហេតុនៃបញ្ហាច្បាស់លាស់
- ប្រជាពលរដ្ឋមានទំនុកចិត្ត ដោយបានចូលរួមកំណត់សកម្មភាពកែលម្អ រួមគ្នាជាមួយអ្នកផ្តល់សេវា
- ឃុំខ្លះ សមាសភាពអ្នកផ្តល់សេវាចូលរួមបានតិច

14

## កិច្ចប្រជុំរួម និងផែនការសកម្មភាពគណនេយ្យភាពរួម

(ផ.ស.គ.រ/JAAP)

- អ្នកផ្តល់សេវាភាគច្រើនទទួលស្គាល់ បើកចំហ និងចូលរួមដំណើរការដាក់ពិន្ទុ ហើយបានរៀបចំ ផ.ស.គ.រ
- ផែនការសកម្មភាពគណនេយ្យភាពរួមឆ្លើយតបតម្រូវការរបស់ពលរដ្ឋ
- ស្ត្រីចូលរួមច្រើនក្នុងគណៈកម្មការ JAAP
- យឺតក្នុងការដាក់បញ្ចូល JAAPក្នុង CIP និង DIPដែលជួយក្នុងការឆ្លើយតបបញ្ហារបស់ពលរដ្ឋ
- គណៈកម្មការត្រួតពិនិត្យផែនការសកម្មភាពគណនេយ្យភាពរួមដែលបានបង្កើតជួយត្រួតពិនិត្យការអនុវត្ត JAAP

15

## បញ្ហាប្រឈម

- ឃុំខ្លះមិនមានអ្នកបកប្រែភាសាជនជាតិក្នុងដំណើរការដាក់ពិន្ទុ
- សមត្ថភាព CAFs នៅមានកម្រិតក្នុងការសម្របសម្រួលកិច្ចប្រជុំ
- ពេលវេលាអនុវត្តខ្លី និងចំពេលច្រូតកាត់
- ឃុំខ្លះអ្នកផ្តល់សេវាទាំងបីចូលរួមបានតិច ហើយមួយចំនួនមិនមែនជាអ្នកសម្រេចចិត្ត
- អ្នកផ្តល់សេវាទាំងបីមួយចំនួនយល់ដឹងតិចតួចពីដំណើរការដាក់ពិន្ទុ
- កញ្ចប់ព័ត៌មាន (I4C)បានបិទផ្សព្វផ្សាយតិចតួច និងរយៈ

16

# បញ្ហាប្រឈម

- អ្នកផ្តល់សេវាទាំងបីស្ទាក់ស្ទើរដាក់ពិន្ទុខ្លួនឯង និងដាក់ពិន្ទុខ្ពស់
- ប្រជាពលរដ្ឋស្ទាក់ស្ទើរ (មិនហ៊ាន) ផ្តល់យោបល់កែលំអក្នុងពេលកិច្ចប្រជុំជាមួយអ្នកផ្តល់សេវា (ឃុំខ្លះ)
- អ្នកផ្តល់សេវាខ្លះមិនទទួលយកសកម្មភាពកែលំអពីប្រជាពលរដ្ឋ
- គណៈកម្មការត្រួតពិនិត្យ ផ.ស.គ.រ ខ្លះមិនយល់ពេញលេញពីតួនាទី
- ផ.ស.គ.រ ដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគប្រចាំឆ្នាំមិនទាន់ពេល

17

# ចំណុចកែលំអ - វិធីសាស្រ្តជ្រើសរើស CAFs

- ផ្សព្វផ្សាយការជ្រើសរើសដែលបញ្ជាក់ពីផលប្រយោជន៍ គោលបំណង និងការទទួលខុសត្រូវជាក់លាក់ (ដោយទុកពេលវេលាសមស្រប)
- ជ្រើសរើស CAFs ដែលជាអង្គការសហគមន៍មូលដ្ឋាន ហើយបើអាចរកអ្នកចេះភាសាក្នុងតំបន់
- ផ្តល់ថវិកាគាំទ្រដល់ CAFsសម្រាប់ធ្វើដំណើរ និងអាហារ
- ទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន និងសហគមន៍

18

## ចំណុចកែលំអ -វិធីសាស្ត្រពង្រឹងសមត្ថភាព CAFs

- បង្កើនពេលវេលាសម្រាប់បណ្តុះបណ្តាល និងបង្រៀនមេរៀនចាំបាច់
- បង្កើនការពិភាក្សាក្រុមតូច និងការអនុវត្តជាក់ស្តែងឲបានច្រើនក្នុងពេល បណ្តុះបណ្តាល (រៀនបណ្តើរ អនុវត្តបណ្តើរ)
- បង្កើនការបង្ហាត់បង្ហាញដល់ CAFs ឲបានច្រើនមុននឹងអនុវត្តសកម្មភាព
- ពេលវេលាសមស្របសម្រាប់បណ្តុះបណ្តាល
- មានទស្សនៈកិច្ចសិក្សាពីឃុំមួយទៅឃុំមួយ
- លិខិតបញ្ជាក់ការសិក្សា

19

## ចំណុចកែលំអ-វិធីសាស្ត្រកៀរគរពលរដ្ឋចូលរួម

- ផ្សព្វផ្សាយពីសារៈសំខាន់ពីការចូលរួម និងផ្តល់យោបល់ក្នុងដំណើរការ ប័ណ្ណដាក់ពិន្ទុតាមរយៈមេក្រូ និងប្រជុំតាមភូមិ
- CAFs អង្គការសហគមន៍មូលដ្ឋាន ក្រុមប្រឹក្សាឃុំ និងមេភូមិចុះជួបផ្ទាល់ជាមួយប្រជាពលរដ្ឋតាមភូមិ
- លិខិតអញ្ជើញ (តាមគ្រួសារ)ដោយបញ្ជាក់ពីទីកន្លែង និងពេលវេលានៃកិច្ចប្រជុំ
- ទីកន្លែងកិច្ចប្រជុំនៅជិតពលរដ្ឋ
- ផ្តល់អាហារសម្រន់ឲបានច្រើនក្នុងកិច្ចប្រជុំ
- បន្តផ្តល់ព័ត៌មានពីការអនុវត្ត ផ.ស.គ.រ (ទាក់ទាញការចូលរួមដាក់ពិន្ទុលើកក្រោយ)

20

## ចំណុចកែលំអ-វិធីសាស្រ្តកៀរគរការគាំទ្រ និងចូលរួមពី មន្រ្តីអប់រំ សុខាភិបាល ស្រុក ខេត្ត

**ថ្នាក់ជាតិ**

- លេខាធិការដ្ឋាន គ.ជ.អ.ប ចេញលិខិតណែនាំដល់ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលខេត្តចារបញ្ជូនលិខិតណែនាំបន្តដល់មន្ទីរ និងការិយាល័យពាក់ព័ន្ធ
- លេខាធិការដ្ឋានបង្កើនវគ្គបណ្តុះបណ្តាលដល់មន្រ្តីសេវាទាំងបីនៅថ្នាក់ខេត្ត ស្រុក ឲបានយល់ពីដំណើរការអនុវត្តផែនការគណនេយ្យភាពសង្គម

**ថ្នាក់ខេត្ត**

- រដ្ឋបាលខេត្តចេញលិខិតណែនាំបន្តដល់មន្ទីរ និងការិយាល័យពាក់ព័ន្ធ

21

## ចំណុចកែលំអ-វិធីសាស្រ្តកៀរគរការគាំទ្រ និងចូលរួមពី មន្រ្តីអប់រំ សុខាភិបាល ស្រុក ខេត្ត

**អ្នករៀបចំ/អង្គការដៃគូ**

- សហការផ្សព្វផ្សាយព័ត៌មាន និងលិខិតអញ្ជើញដល់អ្នកពាក់ព័ន្ធថ្នាក់ស្រុក និងឃុំ
- សហការជាមួយស្រុកក្នុងការពិភាក្សាជាមួយមន្ទីរ និងការិយាល័យ សុខាភិបាល អប់រំ ក្រុមប្រឹក្សាឃុំដើម្បីពន្យល់ពីផលប្រយោជន៍ និងដំណើរការប័ណ្ណដាក់ពិន្ទុ
- ចូលរួមចែករំលែកផែនការអនុវត្តដល់អ្នកពាក់ព័ន្ធ
- បន្តរំលឹកពីកាលបរិច្ឆេទនៃកិច្ចប្រជុំ

22

## ចំណុចកែលំអ-វិធីសាស្ត្រអនុវត្ត JAAP

- ដាក់បញ្ចូលផែនការ JAAP ក្នុង CIP/DIP
- ដាក់បញ្ចូលរបៀបវារៈនៃ JAAP ក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា
- ប្រជុំឆ្លុះបញ្ចាំងលទ្ធផលអនុវត្ត JAAP និងកំណត់ផែនការបន្ត
- បិទផ្សាយ JAAP ជាសាធារណៈ និងបង្ហាញក្នុងវេទិកាសាធារណៈ
- ស្វែងរកការគាំទ្របច្ចេកទេស និងធនធានពីស្ថាប័នខាងក្រៅក្នុងការ    អនុវត្តJAAP
- ផ្សព្វផ្សាយលទ្ធផលអនុវត្ត JAAP ៣ខែម្តងដល់ពលរដ្ឋ
- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត JAAP

23

## ករណីសិក្សា

មានភ្ជាប់ជូន

24

## សេចក្តីសង្ខេប

- ✓ ដំណើរការដាក់ពិន្ទុពហុវិស័យជាវិធីសាស្ត្រវិជ្ជមានមួយក្នុងការលើកកម្ពស់ការចូលរួម និងផ្តល់ត្រឡប់ពីប្រជាពលរដ្ឋ (បើកចំហ ពិភាក្សាផ្ទាល់ជាមួយអ្នកផ្តល់សេវា)
- ✓ ប្រជាពលរដ្ឋដែលបានចូលរួមពេញចិត្តពីដំណើរការដាក់ពិន្ទុនេះ
- ✓ យកចិត្តទុកដាក់លើការផ្សព្វផ្សាយព័ត៌មានឲបានច្រើន (I4C) មុនដាក់ពិន្ទុ
- ✓ ក្រុមប្រឹក្សា និងអ្នកផ្តល់សេវាភាគច្រើនបើកចំហទទួលយោបល់ក្រោយពីបានឆ្លងកាត់ដំណើរការដាក់ពិន្ទុលើកទី១
- ✓ បន្តពង្រឹងសមត្ថភាពអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ឲមានទំនុកចិត្តក្នុងការបំពេញភារៈកិច្ចរបស់ខ្លួន

25

## ផែនការអនុវត្តឆ្នាំ ២០១៥

- ✓ បន្តបង្ហាត់បង្ហាញដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ទាំង១១២នាក់
- ✓ បន្តគាំទ្រការប្រជុំតាមដានការអនុវត្តផែនការគណនេយ្យភាពរួមក្នុង៤៩ឃុំ (៥ស្រុក)

26